# សេចក្តីប្រកាសព័ត៌មានរួម

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃព្រហស្បតិ៍ ទី ២៥ ខែ មីនា ឆ្នាំ ២០១០

# គោលនយោបាយការងារ និងកិច្ចការពារសង្គមត្រូវការជាចាំបាច់ដើម្បីជួយ កម្មករនិយោជិតកាត់ដេរឱ្យធូរស្រាលពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច

ភ្នំពេញ ប្រទេសកម្ពុជា- បើក្រឡេកមើលពីខាងក្រៅ កម្មករនិយោជិតកាត់ដេរដែលមិនត្រូវបានគេបញ្ឈប់ពីការងារដោយសារតែបញ្ហាវិបត្តិសេដ្ឋកិច្ចនោះ គួរតែត្រូវចាត់ទុកថាជាអ្នកមានសំណាង។ ប៉ុន្តែទិន្នន័យថ្មីដែលបានមកពីការសិក្សាមួយដឹកនាំដោយអង្គការពលកម្មអន្តរជាតិ (ILO) បង្ហាញថា បើទោះជាអ្នកទាំងនោះមិនបាន បាត់បង់ការងារក៏ពិតមែន ក៏ពួកគាត់ទទួលរងនូវផលប៉ះពាល់នេះផងដែរ។ ពោលគឺមានកម្មករនិយោជិតជាច្រើនបានទទួលប្រាក់ខែតិចជាងមុន ហើយឥឡូវនេះ ត្រូវតស៊ូដើម្បីទប់ទល់នឹងការចំណាយក្នុងការរស់នៅ។

ការសិក្សានេះ បានធ្វើការវាយតម្លៃលើកម្មករនិយោជិតដែលមានការងារធ្វើចំនួន ១២០០នាក់ និងកម្មករនិយោជិតដែលគ្មានការងារធ្វើចំនួន ៨០០នាក់ ដែលស្នាក់នៅក្នុងទីក្រុងភ្នំពេញ។ ការសិក្សានេះមានបំណងបង្កើនការយល់ដឹងលើការលំបាកដែលកម្មករនិយោជិតកំពុងតែប្រឈម ដោយសារតែឱនភាពសេដ្ឋកិច្ច ក៏ដូចជាយន្តការដោះស្រាយ និងយុទ្ធសាស្ត្រស្វែងរកការងាររបស់ពួកគេ នៅពេលដែលពួកគេត្រូវបានបញ្ឈប់ពីការងារ។

ព័ត៌មានដំបូងត្រូវបាន ប្រមូលចន្លោះពីខែ កញ្ញា ដល់ ខែ ធ្នូ ឆ្នាំ ២០០៩ ហើយបទសម្ភាសន៍ដើម្បីតាមដានបន្តនឹងត្រូវធ្វើឡើងក្រោយរយៈពេល ៣ខែ និង ៦ខែ។ ការសិក្សាលំអិត នឹងបញ្ចប់នៅក្នុងកំឡុងត្រីមាសទី៣ នៃឆ្នាំ ២០១០។

លទ្ធផលពីការអង្កេតដំបូងបង្ហាញថា កម្មករនិយោជិតប្រឈមមុខនឹងការលំបាកជាច្រើន ដែលសំខាន់ជាងគេនោះគឺ ពួកគាត់ទទួលបានប្រាក់ចំណូលតិចជាងមុន ក្នុងឆ្នាំ២០០៩ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨ ។ ឥឡូវនេះកម្មករនិយោជិតគិតថា ពួកគេមិនមានលុយគ្រប់គ្រាន់ទេ ដើម្បីផ្ញើរទៅក្រុមគ្រួសារ និងដើម្បីចំណាយលើតម្រូវចាំបាច់មួយចំនួនដូចជាចំណីអាហារ ការថែទាំសុខភាព និងការធ្វើដំណើរ។ កម្មករនិយោជិតមួយចំនួនដែលត្រូវបាន

គេបញ្ឈប់ពីការងារ ហើយរកបានការងារថ្មី កំពុងតែធ្វើការនៅក្រោមលក្ខខណ្ឌការងារមិនល្អ។ កម្មករនិយោជិតជាច្រើននាក់ដែលត្រូវបានសាកសួរ បានស្វែងរកជំនួយពីសហជីព ដើម្បីឱ្យជួយដោះស្រាយបញ្ហាលំបាកនានា ដូចជាការសុំឈប់សម្រាក និងការបើកប្រាក់ខែយឺត។

នៅក្នុងការសិក្សានេះ កម្មករនិយោជិតដែលគ្មានការងារធ្វើភាគច្រើន បានបាត់បង់ការងារនៅពេលដែលរោងចក្របិទទ្វារ ឬកាត់បន្ថយកម្មករ ដោយសារតែការបញ្ជាទិញត្រូវបានកាត់បន្ថយ។ កម្មករនិយោជិតគ្មានការងារធ្វើម្នាក់ក្នុងចំណោម១០នាក់ ត្រូវបានបញ្ឈប់ពីការងារចំនួន២ដង ឬច្រើនជាងនេះក្នុងឆ្នាំ២០០៩។ បើទោះជាមានកម្មករនិយោជិតមួយចំនួនតូចដែលត្រូវបានបញ្ឈប់ពីការងារ រកបានការងារថ្មីធ្វើហើយក៏ដោយ ក៏ប៉ុន្តែនៅក្នុងកំឡុងពេលនៃការចុះសិក្សា មានកម្មករនិយោជិតភាគច្រើននៅកំពុងតែស្វែងរកការងារធ្វើនៅឡើយ។

ការសិក្សានេះក៏បានបង្ហាញផងដែរថា ជាទូទៅ កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារ បានទៅស្វែងរកការងារ ធ្វើនៅក្នុងរោងចក្រកាត់ដេរផ្សេងៗទៀត ប៉ុន្តែមានតែម្នាក់ក្នុងចំណោម៣នាក់ប៉ុណ្ណោះទទួលជោគជ័យក្នុងការរកបានការងារធ្វើ។ ចំណែកកម្មករនិយោជិតដែលស្វែងរកការងារធ្វើនៅក្រៅពីវិស័យកាត់ដេរ ជាធម្មតាស្វែងរកការងារនៅក្នុងវិស័យសេវាកម្ម ដូចជាអ្នកលក់ផលិតផល អ្នកកាត់ដេរ អ្នកលក់ម្ហូបអាហារ ឬអ្នករត់ម៉ូតូកទុកទុក។ បើទោះជាមានកម្មករនិយោជិតជាច្រើនមានចិត្តចង់ចុះឈ្មោះក្នុងកម្មវិធីបណ្តុះបណ្តាលក៏ដោយ ក៏ប៉ុន្តែមានតែកម្មករនិយោជិតមួយចំនួនតូចប៉ុណ្ណោះដែលបានចុះឈ្មោះ។ ក្រុមគ្រួសាររបស់កម្មករនិយោជិតមួយចំនួន (ទាំងអ្នកមានការងារធ្វើ និងគ្មានការងារធ្វើ) បានបញ្ជូនសមាជិកគ្រួសារបន្ថែមដើម្បីមករកការងារធ្វើក្នុងការជួយដោះស្រាយនូវការធ្លាក់ចុះនៃប្រាក់ចំណូល ដែលភាគច្រើន ជាបងប្អូនស្រីៗ ដែលមានអាយុចន្លោះពី ១៦ឆ្នាំ ដល់ ២៨ឆ្នាំ។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថា បីភាគបួននៃកម្មករនិយោជិតដែលគ្មានការងារធ្វើ បាននិយាយថា ពួកគេនឹងត្រឡប់ទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ ប្រសិនបើពួកគេមិនអាចរកការងារបានធ្វើក្នុងរយៈពេល ៦សប្តាហ៍។

លោក ទ័រម៉ូ ប៉ូទីអែណិន ប្រធានទីប្រឹក្សាបច្ចេកទេសនៃ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* របស់អង្គការពលកម្មអន្តរជាតិ បានមានប្រសាសន៍ថា លទ្ធផលនៃការសិក្សាកំណត់ចំណុចដៅនេះបានបង្ហាញនូវអត្ថប្រយោជន៍រួចទៅហើយ។ លោកបានមានប្រសាសន៍ថា “ព័ត៌មានដែលយើងប្រមូលបានតាមរយៈការសិក្សានេះមានសារៈប្រយោជន៍ សំរាប់ឱ្យអ្នកពាក់ព័ន្ធនានាចាត់ជាវិធានការ ដើម្បីជួយដល់កម្មករនិយោជិតដែលកំពុងរងការលំបាក ពង្រឹងវិស័យកាត់ដេរ និងធ្វើឱ្យប្រទេសកម្ពុជាត្រៀមខ្លួនប្រសើរជាងមុននៅពេលមានវិបត្តិសេដ្ឋកិច្ចទៀតនាពេលអនាគត។”

ដោយផ្អែកតាមលទ្ធផលនៃការសិក្សានេះ និងការស្រាវជ្រាវផ្សេងទៀតដែលពាក់ព័ន្ធនឹងវិបត្តិសេដ្ឋកិច្ច អង្គការ ILO បានកំពុងលើកឡើងនូវអនុសាសន៍មួយចំនួនដែលទាក់ទងនឹងសកម្មភាពរបស់ រដ្ឋាភិបាល និយោជក សហជីព និងដៃគូអភិវឌ្ឍន៍នានា។ ក្នុងនោះ មានការស្នើឡើងនូវ គោលនយោបាយការងារនានា ដើម្បីលើកកម្ពស់ការងារប្រកបដោយផលិតភាពដើម្បីពង្រឹងកិច្ចការពារសង្គម និងដើម្បីធ្វើការជាមួយនិយោជកក្នុងការធ្វើឱ្យប្រសើរ

នូវការអនុលោមទៅតាមច្បាប់ការងារ។ អង្គការ ILO ក៏ស្នើផងដែរឱ្យមានការពិគ្រោះយោបល់បន្តទៀត រវាងនិយោជក និងសហជីព នៅក្នុងកំឡុងពេលការបញ្ឈប់កម្មករនិយោជិត និងការបិទទ្វាររោងចក្រ។ ដៃគូអភិវឌ្ឍន៍ត្រូវបានជំរុញឱ្យគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសទៅលើកម្មវិធីបណ្តុះបណ្តាលឡើងវិញ កម្មវិធីសង្គម សំរាប់កម្មករនិយោជិត ហើយដើម្បីជួយឱ្យសហជីពផ្តល់នូវដំបូន្មានជាក់ស្តែង និងជំនួយផ្សេងៗទៅដល់សមាជិករបស់ពួកគេ នៅក្នុងកំឡុងពេលនៃគ្រាលំបាកនេះ។

ការសិក្សានេះត្រូវបានធ្វើឡើងដោយវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ (CIDS) និងគ្រប់គ្រងដោយអង្គការពលកម្មអន្តរជាតិ ILO ក្រោមការឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ UNDP។

លទ្ធផលសង្ខេបនៃការស្រាវជ្រាវនេះ បង្ហាញនូវការរកឃើញមួយចំនួនដែលធ្វើឡើងតាមរយៈការធ្វើសម្ភាសន៍ សម្រាប់ការអង្កេតកំណត់ចំណុចដៅ។ លទ្ធផលសង្ខេបនៃការស្រាវជ្រាវ ក៏ដូចជារបាយការណ៍អង្កេតកំណត់ចំណុចដៅពិស្តារអាចរកបាននៅលើគេហទំព័ររបស់ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* តាមរយៈ www.betterfactories.org។ នេះគឺជាលទ្ធផលសង្ខេបនៃការស្រាវជ្រាវជាស៊េរីជាលើកដំបូងដែលនឹងត្រូវដាក់បង្ហាញនៅលើគេហទំព័រដើម្បីបង្ហាញពីការស្រាវជ្រាវរបស់អង្គការ ILO ដែលទាក់ទងនឹងវិបត្តិនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក
លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*
នៃអង្គការពលកម្មអន្តរជាតិ
ទូរស័ព្ទលេខ: ០១២ ៩០២ ៩៩០
អ៊ីម៉េល: ying@ilo.org